# មេរៀនទី ២៧: ព្រះបង្កើតផែនដី

## លោកុប្បត្តិ ១:១-២:៣

**គោលបំណង៖** ការបង្កើតរបស់ព្រះគឺអស្ចារ្យ។

**ខគម្ពីរចងចាំ៖ លោកុប្បត្តិ ១:១** “*កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី។*”

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
តើអ្វីនៅក្នុងធម្មជាតិធ្វើឲ្យអ្នកភ្ញាក់ផ្អើល? មហាសមុទ្រ? ពណ៌ស្រស់ស្អាតរបស់ត្រី? ព្រៃដ៏ធំល្វឹងល្វើយ? សូមចំណាយពេលខ្លះដើម្បីកោតសរសើរពីការបង្កើតនៃការរចនារបស់ព្រះ ហើយសូមពិចារណាថាតើព្រះរចនាជីវិតរបស់អ្នកដោយរបៀបណាដែរ។ សូមបង្ហាញក្ដីស្រឡាញ់នៃការបង្កើតរបស់ព្រះ ទៅកាន់កុមារនៅក្នុងសាលាថ្ងៃអាទិត្យ ហើយជួយពួកគេឱ្យមើលទៅព្រះអាទិករដែលបានបង្កើតធម្មជាតិ និង ជីវិតទាំងឡាយ ហើយបានផ្ដល់នូវជីវិតថ្មីសម្រាប់ពួកគតាមរយៈព្រះយេស៊ូវផងដែរ។

**ចំរៀង៖** ១. នេះគឺជាថ្ងៃ ២.តើអ្នកណាជាម្ចាស់នៃខ្ញុំ ៣. អ្នកណាបង្កើតពន្លឺថ្ងៃ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ទឹក គោក អាកាស»**

១. ឲ្យកុមារឈរជារង្វង់ ហើយគ្រូឈរនៅក្នុងរង្វង់នោះធ្វើជាអ្នកចាំទីមុន



២. គ្រូត្រូវដើរក្នុងរង្វង់នោះដោយនិយាយពាក្យថា “ទឹក គោក អាកាស”។ នៅពេលដែលគ្រូចង្អុលកុមារណាម្នាក់ កុមារនោះត្រូវនិយាយឈ្មោះសត្វមួយដែលរស់នៅក្នុងបរិយាកាសដែលគ្រូបានរើស។ ឧទាហរណ៍៖ ប្រសិន បើគ្រូនិយាយថា “គោក” នោះកុមារត្រូវហៅឈ្មោះសត្វមួយដែល រស់នៅលើគោក។ ប្រសិនបើគ្រូ និយាយថា “អាកាស” កុមារត្រូវហៅឈ្មោះសត្វដែលរស់នៅក្នុងអាកាស។

៣. ប្រសិនបើកុមារមិនអាចហៅឈ្មោះសត្វមួយណាបានក្នុងរយៈពេល៣វិនាទី នោះគេនឹងចាញ់ល្បែងនេះ

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះបានបង្កើតអ្វីគ្រប់យ៉ាងដែលយើងអាចមើលឃើញនៅក្នុងផែនដីនេះ។

**៤. ការណែនាំមេរៀន**

តើសត្វមួយណាដែលជាសត្វអស្ចារ្យជាងគេនៅលើផែនដីនេះ? ដំរីធំឬ? សត្វតោដ៏កាចសាហាវឬ? ឬ សត្វទន្សាយឆ្លាតវៃ? គ្រប់សត្វទាំងអស់ និងគ្រប់អ្វីៗទាំងអស់ដែលព្រះបានបង្កើតមកនៅលើលោកិយ៍នេះគឺសុទ្ធតែអស្ចារ្យ។ នេះគឺជាព្រះពរ និងជាអំណោយដ៏វិសេស។ ថ្ងៃនេះយើងនឹងរៀន ថាតើព្រះបានបង្កើតអ្វីគ្រប់យ៉ាងនៅលើផែនដីនេះដោយរបៀបណា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មុនពេលព្រះបង្កើតផែនដីនេះ គ្រប់យ៉ាងនៅជាងងឹត និងទទេស្អាត ហើយវាគ្មានអ្វីទាំងអស់។ ព្រះចង់បង្កើតអ្វីម្យ៉ាងដើម្បីចែកចាយនូវសេចក្តីស្រឡាញ់ និងការល្អរបស់ទ្រង់។

នៅថ្ងៃទី១ ព្រះបានបង្កើតពន្លឺ។ បន្ទាប់ពីព្រះបានបង្កើតពន្លឺរួចហើយទ្រង់ក៏មានបន្ទូលថា "ល្អហើយ"។ ថ្ងៃ ទី២ ព្រះបានបង្កើតផ្ទៃមេឃ។ ថ្ងៃទី៣ ព្រះបានបង្កើតដីគោក រុក្ខជាតិ និងសមុទ្រ។ ថ្ងៃទី៤ ព្រះបានបង្កើត ឲ្យ មានពន្លឺនៅលើមេឃ។ ថ្ងៃទី៥ ព្រះបានបង្កើតសត្វស្លាប និងសត្វផ្សេងៗនៅក្នុងទឹក។ ថ្ងៃទី៦ ព្រះបាន បានបង្កើតសត្វលើដីគោក និងមនុស្ស។ ដែលនៅពេលនោះមនុស្សដំបូងត្រូវបានបង្កើត គឺអ័ដាម និង អេវ៉ា។ បន្ទាប់ពីព្រះបានបង្កើតមនុស្សដំបូងហើយ ទ្រង់មានបន្ទូលថា "ល្អហើយ"។ ព្រះស្រឡាញ់មនុស្ស ហើយព្រះអង្គគិតថាយើងទាំងអស់គ្នាពិសេស។

នៅថ្ងៃទី៧ ព្រះបានធ្វើអ្វីដែលពិសេស៖ ទ្រង់បានសំរាក។ ព្រះសំរាកមិនមែនដោយសារតែទ្រង់អស់កម្លាំងទេ គឺដោយព្រោះតែទ្រង់ចង់ប្រទានពរដល់ការបញ្ចប់នៃការបង្កើតរបស់ទ្រង់។ ហើយទ្រង់ក៏ធ្វើឲ្យថ្ងៃនេះជាថ្ងៃដែលព្រះបង្កើតដើម្បីថ្វាយបង្គំទ្រង់។ ហេតុនេះហើយយើងតែងតែរក្សាថ្ងៃអាទិត្យជាថ្ងៃដែលយើង មកព្រះវិហារដើម្បីថ្វាយ-បង្គំទ្រង់។ យើងថ្វាយបង្គំទ្រង់ក៏ព្រោះតែទ្រង់ជាព្រះដ៏អស្ចារ្យដែលបានបង្កើតអ្វីៗដ៏អស្ចារ្យជាច្រើន!

ព្រះបានបង្កើតអ្វីគ្រប់យ៉ាងដូច្នេះទ្រង់សមនឹងទទួលបាននូវការលើកដំកើង។ គ្រប់យ៉ាងដែលព្រះបង្កើតគឺ អបអរសាទរភាពអស្ចារ្យរបស់ទ្រង់ ព្រះអាទិត្យ ព្រះច័ន្ទ និងឋានសួគ៌ ហើយជាពិសេសយើងទាំងអស់គ្នា! យើងអាចឃើញពីសិរីល្អរបស់ព្រះនៅក្នុងគ្រប់អ្វីដែលព្រះបានបង្កើត។ សូមប្រើពេលខ្លះនៅថ្ងៃនេះ ដើម្បីសម្លឹងមើលទៅការបង្កើតរបស់ព្រះ ហើយសរសើរដំកើងទ្រង់សំរាប់ភាពអស្ចារ្យរបស់ព្រះអង្គ។

## ៦. សំនួរពិភាក្សា

១. តើមានអ្វីនៅទីនោះមុនការបង្កើត? *ភាពងងឹត*

២. តើអ្វីជាវត្ថុដំបូងដែលព្រះបានបង្កើត? *ពន្លឺ*

៣. តើអ្វីជារបស់ចុងក្រោយដែលព្រះបានបង្កើត? *មនុស្ស*

៤. តើអ្នកគិតថាអ្វីដែលអស្ចារ្យបំផុតដែលព្រះបានបង្កើត? *ឱ្យកុមារឆ្លើយ*

## ៧. ល្បែងកំសាន្ត «ស្វែងរកការបង្កើត»

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសរូបភាពនៃការបង្កើត




១. បិតរូបទាំង៧នៅលើជញ្ជាំងតាមលេខរៀង មុនពេលដែលកុមារមកដល់ព្រះវិហារ។

២. ឲ្យកុមារឈរនៅកណ្តាល ហើយពេលដែលគ្រូរំលឹកពីការបង្កើត ពួកគេត្រូវរត់ទៅរករូបភាពនៅលើជញ្ជាំង ឧទាហរណ៍៖ បើសិនជាគ្រូនិយាយថា

“ទន្សាយ” កុមារត្រូវរត់ទៅរកថ្ងៃទី៦។ បើសិនជាគ្រូ និយាយថា “ចេក” កុមារត្រូវរត់ទៅរកលេខ៣។ (គ្រូត្រូវធ្វើបញ្ជីនៃការបង្កើតសំរាប់ថ្ងៃនីមួយៗដើម្បីលេងល្បែងនេះ)
៣. ពេលគ្រូនិយាយថា  “ឈប់” គ្រប់គ្នាត្រូវតែឈប់នៅកន្លែងដែលគេឈរ ហើយបើសិនពួកគេឈរនៅក្បែរកន្លែងថ្ងៃខុស ពួកគេនិងចាញ់ល្បែងនេះ។
៤. បន្ទាប់ពីលែងល្បែងនេះចប់ សូមពន្យល់កុមារថា យើងត្រូវតែថ្វាយបង្គំ និងសរសើរដំកើងព្រះជានិច្ចសំរាប់ការបង្កើតដ៏អស្ចារ្យរបស់ទ្រង់។

| | |
|---|---|
| **៨. ខគម្ពីរចងចាំ** | **លោកុប្បត្តិ ១:១** |

| | |
|---|---|
| **៩. ហត្ថកម្ម** | **« ព្រះបង្កើតផែនដី»** |



**សម្ភារះដែលត្រូវការ៖** បោះពុម្ពក្រដាស, កូល័រ, កន្ត្រៃ, កាវបិត
១. ចែកក្រដាសហត្ថកម្មដែលបានបោះពុម្ពទៅកុមារម្នាក់ ១សន្លឹក ហើយឱ្យពួកគេ ផាត់ពណ៌លើគ្រប់ថ្ងៃនៃការបង្កើត។
២. ឱ្យកុមារកាត់រង្វង់ហើយបត់វាពាក់កណ្តាល។
៣. កុមារគួរបិតចំណងជើងពាក់កណ្តាល និងថ្ងៃទី ១ ជាមួយគ្នា។ បន្ទាប់មកបិតថ្ងៃទី២ជាមួយថ្ងៃទី១ និងបិតបន្តបន្ទាប់។ ហើយចុងក្រោយឲ្យកុមារបិតថ្ងៃទី៧ជាមួយនឹងចំណងជើងហើយធ្វើវាឲ្យក្លាយជាបាល់។ (ជម្រើស៖ អ្នកអាចដាក់ខ្សែអំបោះនៅចំកណ្តាលមុនពេលបិតថ្ងៃទី ៧ ជាមួយនិងចំណងជើង ដើម្បីងាយស្រួលសំរាប់កុមារយកតាមខ្លួន)។
៤. សូមពន្យល់កុមារថាការបង្កើតរបស់ព្រះគឺអស្ចារ្យណាស់!

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*






១. ចែកក្រដាសហត្ថកម្មដែលបានបោះពុម្ពទៅកុមារម្នាក់ ១ ហើយឱ្យពួកគាត់ផាត់ពណ៌លើគ្រប់ថ្ងៃនៃការបង្កើត។

២. ឱ្យកុមារកាត់រង្វង់ហើយបត់វាពាក់កណ្ដាល។ ៣. កុមារគួរបិតចំណងជើងពាក់កណ្ដាល និងថ្ងៃទី ១ ជាមួយគ្នា។ បន្ទាប់ មកបិតថ្ងៃទី២ ជាមួយថ្ងៃទី១ និងបិតបន្តបន្ទាប់។ ហើយចុងក្រោយឲ្យកុមារបិតថ្ងៃទី៧ជាមួយនឹងចំណង ជើងហើយធ្វើវាឲ្យក្លាយបាល់។

(ជម្រើស៖ អ្នកអាចដាក់ខ្សែអំបោះនៅចំកណ្ដាលមុនពេលបិតថ្ងៃទី ៧ ជាមួយនិងចំណងជើង ដើម្បីងាយស្រួលសំរាប់កុមារយកតាមខ្លួន)។